# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ជំនះខ្លួនឯងជាជំនះប្រសើរបំផុត

www.hoksavann.org

ថ្ងៃទី២ កុម្ភៈ ២០១១



មានគាថាមួយបទនៅក្នុងធម៌បទនៃគម្ពីរព្រះពុទ្ធសាសនាថា សូម្បីបុគ្គលអាចយកជ័យជំនះលើមនុស្សរាប់ពាន់នាក់ ក្នុងសង្គ្រាមរាប់ពាន់ដងក៏ដោយ ក៏ពុំប្រសើរជាងការឈ្នះលើខ្លួនឯងសូម្បីតែម្តងឡើយ បុគ្គលឈ្នះខ្លួនឯងឈ្មោះថាជាអ្នកឈ្នះសង្គ្រាមដ៏ប្រសើរបំផុត ។

តាមផ្ទៃនៃគាថានេះ គេអាចចែកជាពីរ គឺជំនះដោយចំបាំងតាមសមរភូមិផ្លូវលោក និងជំនះដោយចំបាំងតាមសមរភូមិផ្លូវធម៌ ។ ចំពោះជំនះដោយចំបាំងតាមសមរភូមិផ្លូវលោកបានដល់គាថាខាងដើមថា សូម្បីបុគ្គលអាចយកជ័យជំនះលើមនុស្សរាប់ពាន់នាក់ ក្នុងសង្គ្រាមរាប់ពាន់ដងពុំប្រសើរឡើយ ។ បានសេចក្តីថា ការឈ្នះអ្នកដទៃដោយកម្លាំងយុទ្ធវិធី ពុំអាចធ្វើឲ្យអ្នកចាញ់ សុខចិត្តឡើយ ។ សង្គ្រាមអាចកើតឡើងនៅពេលណាមួយទៀត ឱកាសដែលអ្នកចាញ់ប្រមូលកម្លាំងបាន ។ ដូច្នេះជំនះបែបនេះ បើជាជំនះប្រកបដោយអំពើអយុត្តិធម៌ផង ជាជំនះពុំអាចស្ថិតនៅយូរអង្វែងឡើយ ។ ជ័យជំនះដោយអំពើរំលោភបំពាន ដែលជាការរំលោភសិទ្ធិ ជាជំនះត្រឡប់ចាញ់វិញនៅទីបំផុត ។ ឧទាហរណ៍ ហ៊ីត្លែរនៃគណបក្សណាស៊ីអាល្លឺម៉ង់ ដែលប្រហារជីវិតមនុស្សអស់ជាច្រើននៅក្នុងសង្គ្រាមលោក ទោះបីហ៊ីត្លែរស្លាប់ទៅហើយក៏ដោយ ក៏សមាជិកខ្លះនៃគណបក្សនេះ ត្រូវតុលាការអន្តរជាតិតាមចាប់យកមកកាត់ទោសរហូតមកដល់សព្វថ្ងៃនេះ ។ក្នុងករណីដូចគ្នានេះដែរ មេពេជ្ឈឃាតខ្មែរក្រហម ដែលធ្វើឃាតព្រះសង្ឃ និងជនជាតិ ខ្មែររាប់លាននាក់ ត្រូវតុលាការចំរុះអន្តរជាតិកាត់ទោស ពុំអាចគេចខ្លួនរួចឡើយ ។ នេះជាមេរៀនប្រវត្តិសាស្ត្រប្រាប់មកខ្មែរជំនាន់ក្រោយៗមកទៀត កុំប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សក្រៅច្បាប់ នឹងត្រូវទទួលទោសទណ្ឌកម្មពុំខានឡើយ ។ បើពោលតាមផ្លូវព្រះធម៌នៃព្រះពុទ្ធសាសនាវិញ អ្នកប្រព្រឹត្តអំពើឧក្រិដ្ឋរំលោភសិទ្ធិមនុស្ស បើទោះបីបិទបាំងតុលាការមិនទាន់យក មកកាត់ទោសក៏ដោយ ក៏ទទួលទោសទុក្ខរួចទៅហើយ រស់នៅដោយការភិតភ័យ ដេកផ្លាស់កន្លែង គ្មានសុភមង្គលឡើយ ស្លាប់ទៅនឹងធ្លាក់ទៅសោយទុក្ខក្នុងនរកដូចគេច្រានទម្លាក់ ។

គាថាក្នុងវគ្គទី២ថា បុគ្គលឈ្នះខ្លួនឯង ឈ្មោះថាជាអ្នកឈ្នះសង្គ្រាមដ៏ប្រសើរបំផុត ។ ពាក្យនៃគាថាខាងចុងនេះ ចាត់ជាជំនះដោយចំបាំងតាមសមរភូមិផ្លូវធម៌ ។ ចំបាំងផ្លូវធម៌ ពុំមែនច្បាំងកាប់សម្លាប់អ្នកដទៃឡើយ គឺច្បាំងសម្លាប់សេចក្តីអាក្រក់បានដល់កិលេសតណ្ហា ដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនវិញទេ ។ ការប្រយុទ្ធគឺការព្យាយាមលះបង់ខ្មាំងសត្រូវ បានដល់កិលេសតណ្ហានិងអំពើអាក្រក់គ្រប់យ៉ាង ។ការប្រយុទ្ធនឹងកិលេសតណ្ហា ប្រៀបដូចធ្វើចំបាំង ព្រោះកិលេសតណ្ហានេះ មានកម្លាំងមានឥទ្ធិពលខ្លាំងណាស់ បើព្យាយាមល្មមៗពុំអាចលះបង់បានឡើយ ។ សមរភូមិផ្លូវធម៌ ដែលច្បាំងនឹងកិលេសតណ្ហា មានការពិបាកច្បាំងជាងខ្មាំងសត្រូវ ដែលជាសមរភូមិផ្លូវលោកទៅទៀត ។ ប៉ុន្តែកិលេសតណ្ហាណាដែលព្រះអរិយបុគ្គលមានសោតាបន្នបុគ្គលជាដើមច្បាំងឈ្នះ គឺលះបង់បានហើយ និងមិនត្រឡប់ចាញ់វិញ គឺមិនត្រឡប់កើតវិញឡើយ ។ ចំណែកមនុស្សសត្វដែលនៅជាបុថុជ្ជន ពុំងាយលះបានឡើយ ព្រោះពុំទាន់ឃើញទោសច្បាស់នូវកិលេសតណ្ហា បើលះបានក្នុងពេលខ្លះ ក៏ពេលក្រោយអាចកើតឡើងវិញ ព្រោះបញ្ញាដែលកើតពីការប្រតិបត្តិនូវព្រះធម៌នៅទន់ខ្សោយ ។ បានជាព្រះសម្ពុទ្ធបង្រៀនឲ្យមនុស្សសត្វ លះនូវកិលេសតណ្ហានេះ ព្រោះជាឫសគល់ឲ្យមនុស្សសត្វសាងបាបកម្ម ដែលនាំឲ្យមានវិបាកវិលស្លាប់កើតក្នុងសង្សារវដ្តរកទីបំផុតគ្មាន ។

គាថានេះជាការប្រៀបធៀបគ្នា រវាងជំនះដោយការប្រកួតប្រជែងគ្នារហូតធ្វើចំបាំងកាប់សម្លាប់គ្នា ជាជំនះពុំប្រសើរ ព្រោះនាំឲ្យចងគំនុំនឹងគ្នាទៅវិញទៅមក ពុំបានសេចក្តីសុខឡើយ ។ ចំណែកជំនះដែលកើតពីការលះបង់នូវកិលេសតណ្ហាអវិជ្ជាដែលស្ថិតនៅក្នុងចិត្តរបស់មនុស្សសត្វ ជាជំនះប្រសើរ ព្រោះនាំឲ្យរួច ចាកទុក្ខ មានជាតិទុក្ខជាដើម ។គាថាដ៏មានប្រយោជន៍ដ៏សំខាន់នេះ បានប្រាប់ដល់មនុស្សសត្វថា បើគេស្អប់ទុក្ខចង់បានសេចក្តីសុខ គេត្រូវតែអប់រំចិត្តឲ្យស្ងប់អំពើបាប លះបង់ការបៀតបៀន គឺឈ្នះនូវសេចក្តីអាក្រក់របស់ខ្លួន ។ ដូចជាព្រះសម្ពុទ្ធឈ្នះមារ ពុំមែនឈ្នះមារបានដល់ការឈ្នះអ្នកដទៃឡើយ គឺឈ្នះកិលេសដែលស្ថិតនៅក្នុងព្រះទ័យព្រះអង្គ ។ ការឈ្នះអវិជ្ជា តណ្ហា ឧបា ទាន និងកម្ម ដែលជាហេតុនាំឲ្យកើតទុក្ខនេះហើយ ទើបសេចក្តីទុក្ខ គឺការកើតឡើងនៃខន្ធ៥ក៏ត្រូវរលត់ ។៚

☆ ☆

☆